ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣

**អគ្គនាយកដ្ឋានគោលនយោបាយ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ខែកុម្ភៈ ឆ្នាំ២០២៤

# មាតិកា


សេចក្តីអធិប្បាយសង្ខេប ........................................................ ១

តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ................................................ ៤

១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ ................................................ ៤

២. សូចនាករតាមវិស័យ ................................................ ៦

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ................................................ ៦

២.២. អត្រាប្តូរប្រាក់ ................................................ ៧

២.៣. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ ................................................ ៨

២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន ................................................ ១០

២.៥. ស្ថានភាពពាណិជ្ជកម្ម ................................................ ១៤

២.៦. ស្ថានភាពវិនិយោគឯកជន ................................................ ១៨

២.៧. ស្ថានភាពទេសចរណ៍ ................................................ ១៩

២.៨. ស្ថានភាពសំណង់ ................................................ ២១

៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ ................................................ ២២

# សេចក្តីអធិប្បាយសង្ខេប

ស្ថានភាពសេដ្ឋកិច្ចសកល ត្រូវបានវាយតម្លៃដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) កាលពីខែមករា ឆ្នាំ២០២៤ បង្ហាញថា កំណើននឹងសម្រេចបាន ៣,១% នៅឆ្នាំ២០២៣ និង សម្រេចបាន ៣,១% នៅឆ្នាំ២០២៤។ បើទោះបីជាស្ថានភាពសេដ្ឋកិច្ច នៃបណ្តាប្រទេសមួយចំនួនមានភាពប្រសើរ ដូចជាសហរដ្ឋអាមេរិក ចិន ឥណ្ឌា រុស្ស៊ី ប្រេស៊ីល និងម៉ិកស៊ិក ក៏ដោយក្តី, ក៏ស្ថានភាពសេដ្ឋកិច្ចសកល នៅតែប្រឈមនឹងភាពមិនប្រាកដប្រជាមួយចំនួន ដូចជា ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ, លក្ខខណ្ឌមិនស្វាអំណោយផលក្នុងវិស័យហិរញ្ញវត្ថុ, គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ, ការផ្ទុះសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា, សង្គ្រាមនៅអ៊ុយក្រែនបន្តអូសបន្លាយ និងភាពតានតឹងភូមិសាស្ត្រនយោបាយក្នុងតំបន់ និងសកល។

ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានក្នុងអត្រា ៥,៦%[1] នៅឆ្នាំ២០២៣ ខ្ពស់ជាង ឆ្នាំ២០២២។ អត្រាកំណើននេះ គាំទ្រដោយការរក្សាបានកំណើនល្អ នៃកម្មន្តសាលមិនមែនកាត់ដេរ ដែលបម្រើឱ្យការនាំចេញ និងការប្រើប្រាស់ក្នុងស្រុក, ការកើនឡើងនូវគម្រោងវិនិយោគឯកជន, និងការងើបឡើងគួរឱ្យកត់សម្គាល់នៃវិស័យទេសចរណ៍។ ជាការសង្កេតនៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ សេដ្ឋកិច្ចកម្ពុជា មានកំណើនទាបជាងក្នុងត្រីមាសមុន បន្តិចបន្តួច ដោយសារវិស័យមួយចំនួនមានកំណើនថមថយ និងការធ្លាក់ចុះនៃវិស័យសំណង់ ព្រមទាំងការនាំចេញ។ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ស្ថានភាពសេដ្ឋកិច្ចជារួម រើបឡើង តាមរយៈកំណើនចំនួនភ្ញៀវទេសចរអន្តរជាតិប្រមាណ ៥១%, កំណើនទុននៃគម្រោងវិនិយោគឯកជនប្រមាណ ៣២៨,៧%, កំណើនទឹកប្រាក់នៃការនាំចេញទំនិញ(ដកមាស) ប្រមាណ១០,២% និងស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងអតិផរណាស្ថិតក្នុងកម្រិតទាប។

**អតិផរណា និងអត្រាប្តូរប្រាក់[2]**

អតិផរណាមធ្យមប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ មានអត្រាធ្លាក់ចុះ ០,២% ធៀបនឹងត្រីមាសមុន ប៉ុន្តែបានកើនឡើង ៣,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ដោយសារការកើនឡើង នៃសន្ទស្សន៍ថ្លៃគ្រប់ក្រុមមុខទំនិញ ជាពិសេសសន្ទស្សន៍ថ្លៃម្ហូបអាហារ, សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន, សន្ទស្សន៍ថ្លៃការដឹកជញ្ជូន, សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនីឧស្ម័ន និងឥន្ធនៈដទៃទៀត។ ទន្ទឹមនេះ អត្រាប្តូរប្រាក់ជាមធ្យមក្នុងរង្វង់ ៤ ១១៨,៨ រៀល/ដុល្លារអាម៉េរិក បានធ្លាក់ចុះ ០,៣% ធៀបនឹងត្រីមាសមុន និងបានធ្លាក់ចុះ ០,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ[3]**

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ ការប្រមូលចំណូល អនុវត្តបានសរុបចំនួន ៦ ០១៤,១ ប៊ីលានរៀល (ស្មើ ២៣,២ % នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានកើនឡើង ១១,១% ធៀបនឹងត្រីមាសមុន ប៉ុន្តែ បានធ្លាក់ចុះ ៣,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ក្នុងនោះ ចំណូលចរន្តសរុប ៦ ០០២ ប៊ីលានរៀល បានកើនឡើង ១១% ធៀបនឹងត្រីមាសមុន ប៉ុន្តែ បានធ្លាក់ចុះ ៣,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ដោយសារការធ្លាក់ចុះ នៃការប្រមូលចំណូលសារពើពន្ធ ជាពិសេសពន្ធលើអាករ

[1] ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៤

[2] ទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ និងធនាគារជាតិ នៃកម្ពុជា

[3] ទិន្នន័យពីអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លើតម្លៃបន្ថែមពីការនាំចូល, អាករពិសេស និងចំណូលពន្ធលើការនាំចូល។ រីឯ ចំណាយសរុបអនុវត្តបានចំនួន ៩ ៩៥៥,៦ ប៊ីលានរៀល (ស្មើនឹង ២៨,៧% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានកើនឡើង ៣៩,១% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ១០,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ខណៈដែលចំណាយចរន្តសរុបអនុវត្តបានចំនួន ៦ ១៣១,២ ប៊ីលានរៀល បានកើនឡើង ៣១,៥% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ៩,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ការកើនឡើងនេះ គឺដោយសារការបន្តកើនឡើងលើការចំណាយចរន្ត ដូចជាការចំណាយរដ្ឋបាលស៊ីវិល, ការចំណាយការប្រាក់ និងការបន្តរក្សាចំណាយការពារនិងសន្តិសុខជាតិ។ ជាលទ្ធផល ការអនុវត្តថវិកាចរន្ត មានឱនភាពចំនួន ១២៩,២ ប៊ីលានរៀល។

**ស្ថានភាពរូបិយវត្ថុ និងឥណទាន**[4]

គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០២៣ រូបិយវត្ថុទូទៅ (M2) មានសរុបចំនួន ១៩៣,៥ ទ្រីលានរៀល បានកើនឡើង ៣,៤% ធៀបនឹងត្រីមាសមុន និង បានកើនឡើង ១២,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ខណៈដែលទុនបម្រុងរូបិយប័ណ្ណបរទេសដុល មានសរុបចំនួន ២០ ប៊ីលានដុល្លារអាម៉េរិក បានកើនឡើង ១០,៧% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ១២,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ទន្ទឹមនេះ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ មានសរុបចំនួន ២២១,២ ទ្រីលានរៀល បានកើនឡើង ០,៥% ធៀបនឹងត្រីមាសមុន និង បានកើនឡើង ១៣,៩% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០២២ ដែលភាគច្រើនបានផ្តល់ទៅគ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ ដូចជាការលក់ដុំ-លក់រាយ, ការជួញដូរអចលនទ្រព្យ, ការសាងសង់ និងកសិកម្ម។

**ពាណិជ្ជកម្មក្រៅប្រទេស**[5]

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ បើមិនរាប់បញ្ចូលមាស, ការនាំចេញ មានទឹកប្រាក់សរុបចំនួន ៥ ៦៩៩,២ លានដុល្លារអាម៉េរិក ធៀបនឹងត្រីមាសមុន បានធ្លាក់ចុះ ៥,៤% ដោយសារការធ្លាក់ចុះ នៃការនាំចេញផលិតផលកាត់ដេរ, កង់, គ្រឿងអេឡិចត្រូនិកនិងភាគបំណែក, ខ្សែភ្លើងនិងបង្គុំខ្សែភ្លើង, ស្វាយចន្ទី, ពោតក្រហម និងផលិតផលឧស្សាហកម្មមួយចំនួនទៀត។ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២, ការនាំចេញសរុប បានកើនឡើង ១០,២% គឺដោយសារការរក្សាបានកំណើនល្អ នៃការនាំចេញផលិតផលមិនមែនកាត់ដេរ។ រីឯ ការនាំចូល មានទឹកប្រាក់សរុបចំនួន ៥ ៩៦៦,៤ លានដុល្លារអាម៉េរិក បានធ្លាក់ចុះ ០,៤% ធៀបនឹងត្រីមាសមុន និងបានធ្លាក់ចុះ ២,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ដោយសារការធ្លាក់ចុះ នៃការនាំចូលគ្រឿងសំណង់, យានយន្ត និងគ្រឿងបង្គុំរថយន្ត ជាដើម។

**ទេសចរណ៍**[6]

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ ភ្ញៀវទេសចរផ្ទៃក្នុង ៨,៣ លាននាក់ (ភ្ញៀវទេសចរជាតិ ស្មើនឹង ៩១,៩%) បានកើនឡើង ២២៨,១% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ៣៥,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ទន្ទឹមនេះ ភ្ញៀវទេសចរអន្តរជាតិ មានសរុបចំនួន ១,៥ លាននាក់ បានកើនឡើង ១៣,៣% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ៥១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។

[4] ទិន្នន័យពីធនាគារជាតិ នៃកម្ពុជា

[5] ទិន្នន័យពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

[6] ទិន្នន័យពីក្រសួងទេសចរណ៍

កំណើននេះ គឺដោយសារភ្ញៀវទេសចរអន្តរជាតិ ដែលបានបង្វែរទិសពីតំបន់មជ្ឈិមបូព៌ា និងអឺរ៉ុប ដើម្បីបញ្ចៀសពីផលប៉ះពាល់ នៃសង្គ្រាមនៅអ៊ុយក្រែន និងនៅតំបន់មជ្ឈិមបូព៌ា ព្រមទាំងការដាក់ចេញវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់បន្តការគ្រប់គ្រងផលប៉ះពាល់ និងបន្តគាំទ្រដល់វិស័យទេសចរណ៍។

**វិនិយោគឯកជន**[7]

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ គម្រោងវិនិយោគដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសរុបចំនួន ៥២ គម្រោង បានធ្លាក់ចុះ ៣៣,៣% និងទំហំទុនវិនិយោគ មានសរុបចំនួន ៩៣៦,៧ លានដុល្លារអាម៉េរិក បានធ្លាក់ចុះ ២១,៩% ធៀបនឹងត្រីមាសមុន។ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២, គម្រោងវិនិយោគសរុប បានកើនឡើង ៤៤,៤% និងទំហំទុនវិនិយោគសរុប បានកើនឡើង ៣២៨,៧% ដោយមានការកើនឡើង នៃគម្រោងវិនិយោគលើវិស័យឧស្សាហកម្ម, វិស័យថាមពល និងវិស័យទេសចរណ៍។

**សំណង់**[8]

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ គម្រោងសំណង់ទូទាំងប្រទេស មានសរុបចំនួន ៦០៩ គម្រោង បានធ្លាក់ចុះ ១៨,៧% និងតម្លៃគម្រោងសាងសង់មានសរុបចំនួន ៥០១,៩ លានដុល្លារអាម៉េរិក បានធ្លាក់ចុះ ៧៧,២% ធៀបនឹងត្រីមាសមុន។ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២, គម្រោងសំណង់ទូទាំងប្រទេស បានធ្លាក់ចុះ ៤៤,៦% និងតម្លៃគម្រោងសាងសង់ បានធ្លាក់ចុះ ៥០,៣%។ ការធ្លាក់ចុះនេះ គឺដោយសារការធ្លាក់ចុះ នៃប្រភេទសំណង់លំនៅឋាន, សំណង់ពាណិជ្ជកម្ម, សំណង់ឧស្សាហកម្ម និងសំណង់ទេសចរណ៍។

**ថ្លៃទំនិញសំខាន់ៗ**[9] **លើទីផ្សារអន្តរជាតិ**

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ ថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិគិតជាមធ្យម ដូចជា ថ្លៃអង្ករ ៦១០,៧ ដុល្លារអាម៉េរិក/តោន បានកើនឡើង ១,៧%, ថ្លៃមាស ២ ១៦៧,៤ ដុល្លារអាម៉េរិក/អោន បានកើនឡើង ២,៤%, ថ្លៃកៅស៊ូ (TSR20) ១ ៤៦១,៧ ដុល្លារអាម៉េរិក/តោន បានកើនឡើង ៩,៤%, សន្ទស្សន៍ថ្លៃលោហធាតុមានតម្លៃ ១៤៩,២ បានកើនឡើង ១,៨% ខណៈដែលថ្លៃប្រេងឆៅ ៨២,១ ដុល្លារអាម៉េរិក/ធុង បានធ្លាក់ចុះ ៣,៨%, សន្ទស្សន៍ថ្លៃថាមពល ១០៧,១ បានធ្លាក់ចុះ ១,៨%, សន្ទស្សន៍ថ្លៃមិនមែនថាមពល ១០៧,៨ បានធ្លាក់ចុះ ២,២% ធៀបនឹងត្រីមាសមុន។ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២, ថ្លៃអង្ករ បានកើនឡើង ៣៦,៩%, ថ្លៃកៅស៊ូ (TSR20) បានកើនឡើង ១២,៣%, ថ្លៃមាស បានកើនឡើង ១៤,៣%, សន្ទស្សន៍ថ្លៃលោហធាតុមានតម្លៃ បានកើនឡើង ១៣,២% ប៉ុន្តែថ្លៃប្រេងឆៅ បានធ្លាក់ចុះ ៣,៨%, សន្ទស្សន៍ថ្លៃថាមពល បានធ្លាក់ចុះ ២២,៩% និងសន្ទស្សន៍ថ្លៃមិនមែនថាមពល បានធ្លាក់ចុះ ៥,៧%។

[7] ទិន្នន័យពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

[8] ទិន្នន័យពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[9] ទិន្នន័យពីគេហទំព័រធនាគារពិភពលោក និងសម្គាល់÷សន្ទស្សន៍ថ្លៃថាមពល (ធ្យូងថ្ម, ប្រេងឆៅ និងឧស្ម័ន), មិនមែនថាមពល (លោហធាតុ, កសិកម្ម និងជីគីមី) និងលោហធាតុមានតម្លៃ (មាស, ប្រាក់ និងប្លាទីន)

# តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង ១÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| បរិយាយ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| **សូចនាករមូលដ្ឋាន (ជាមធ្យម)** | | | | | |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | | 203.80 | -0.2% | 3.1% | 2.1% |
| អត្រាប្តូរប្រាក់ | រៀល/ ដុល្លារអាមេរិក | 4,118.78 | -0.3% | -0.2% | 0.5% |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 6,002.03 | 11.0% | -3.9% | -1.6% |
| ចំណាយចរន្ត | ប៊ីលានរៀល | 6,131.21 | 31.5% | 9.1% | 11.9% |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | (129.18) | -117.4% | -120.6% | -36.3% |
| **រូបិយវត្ថុ និងឥណទាន** | | | | | |
| រូបិយវត្ថុទូទៅ (M2) | ប៊ីលានរៀល | 193,530.49 | 3.4% | 12.5% | 10.0% |
| ឥណទាន* | ប៊ីលានរៀល | 242,251.67 | 0.4% | 3.9% | 8.5% |
| ឥណទេយ្យក្នុងស្រុក | ប៊ីលានរៀល | 213,579.65 | 0.4% | 4.8% | 9.6% |
| ទុនបម្រុងរូបិយប័ណ្ណបរទេសសុទ្ធ | លានដុល្លារអាមេរិក | 19,998.38 | 10.7% | 12.3% | -1.0% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | | |
| ទំហំនាំចេញទំនិញ | លានដុល្លារអាមេរិក | 6,007.18 | -2.0% | 15.0% | 5.0% |
| ទំហំនាំចូលទំនិញ | លានដុល្លារអាមេរិក | 6,135.31 | 1.5% | -0.7% | -18.5% |
| តុល្យភាពពាណិជ្ជកម្ម | លានដុល្លារអាមេរិក | (128.12) | -242.5% | -86.6% | -89.2% |
| **វិនិយោគឯកជន** | | | | | |
| គម្រោងវិនិយោគសរុប | គម្រោង | 52 | -33.3% | 44.4% | 30.6% |
| ទុនវិនិយោគ | លានដុល្លារអាមេរិក | 936.66 | -21.9% | 328.7% | 51.0% |
| **ទេសចរណ៍** | | | | | |
| ភ្ញៀវទេសចរអន្តរជាតិ | នាក់ | 1,526,349 | 13.3% | 51.0% | 139.5% |
| ភ្ញៀវទេសចរផ្ទៃក្នុង | នាក់ | 8,344,239 | 228.1% | 35.7% | 35.5% |

| បរិយាយ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| **សំណង់ទូទាំងប្រទេស** | | | | | |
| គម្រោង | គម្រោង | 609 | -18.7% | -44.6% | -25.0% |
| តម្លៃ | លានដុល្លារអាម៉េរិក | 501.85 | -77.2% | -50.3% | 84.0% |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (ជាមធ្យម)** | | | | | |
| អង្ករ (បាក់៥%) | ដុល្លារអាម៉េរិក/ តោន | 610.67 | 1.7% | 36.9% | 26.8% |
| ប្រេងឆៅ** | ដុល្លារអាម៉េរិក/ ធុង | 82.05 | -3.8% | -3.8% | -16.8% |
| កៅស៊ូ (TSR20) | ដុល្លារអាម៉េរិក/ តោន | 1,461.67 | 9.4% | 12.3% | -10.4% |
| មាស | ដុល្លារអាម៉េរិក/ អោន | 2,167.41 | 2.4% | 14.3% | 7.9% |

ប្រភព÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, ធនាគារជាតិនៃកម្ពុជា, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងទេសចរណ៍ និង ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់

សម្គាល់÷ *ឥណទានផ្តល់ដោយធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ, ** ថ្លៃជាមធ្យមរួមប្រេងឆៅ÷ UK Brent, Dubai Fateh និង WTI

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង ២÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាស)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **203.80** | **-0.2%** | **3.1%** | **2.1%** |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 254.66 | 0.2% | 3.7% | 3.2% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 186.29 | 0.8% | 3.8% | 2.4% |
| សម្លៀកបំពាក់ និងស្បែកជើង | 183.34 | 0.4% | 3.5% | 3.1% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 141.94 | -0.1% | 2.5% | 0.4% |
| គ្រឿងសង្ហារិម សម្ភារប្រើប្រាស់ និងការថែទាំ | 163.71 | 0.1% | 1.5% | 1.4% |
| សុខាភិបាល | 142.97 | -0.7% | 0.0% | 0.3% |
| ការដឹកជញ្ជូន | 125.84 | -1.9% | 1.1% | -2.1% |
| គមនាគមន៍ | 66.63 | -0.1% | 0.4% | 0.1% |
| ការកំសាន្ត និងវប្បធម៌ | 133.16 | -0.1% | 3.9% | 3.1% |
| ការសិក្សា | 172.70 | 0.2% | 1.9% | 1.7% |
| ភោជនីយដ្ឋាន | 326.30 | -1.4% | 3.4% | 2.0% |
| ទំនិញ និងសេវាកម្មផ្សេងៗ | 171.80 | 0.2% | 3.0% | 2.2% |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ (ឆ្នាំគោល ២០០៦)

*រូបភាព ១÷ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.២. អត្រាប្តូរប្រាក់

*តារាង ៣÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| អត្រាប្តូរប្រាក់មធ្យមប្រចាំខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2015 | 4,042.67 | 4,055.67 | 4,092.00 | 4,050.67 |
| 2016 | 4,022.67 | 4,054.67 | 4,094.38 | 4,041.72 |
| 2017 | 4,016.14 | 4,047.37 | 4,079.54 | 4,037.16 |
| 2018 | 4,011.98 | 4,046.47 | 4,073.46 | 4,047.26 |
| 2019 | 4,006.33 | 4,052.39 | 4,086.61 | 4,063.09 |
| 2020 | 4,064.19 | 4,087.18 | 4,094.59 | 4,063.78 |
| 2021 | 4,059.22 | 4,063.14 | 4,076.17 | 4,072.04 |
| 2022 | 4,063.26 | 4,056.07 | 4,101.37 | 4,128.65 |
| **2023** | **4,084.16** | **4,103.60** | **4,132.61** | **4,118.78** |

*ប្រភពៈ ធនាគារជាតិនៃកម្ពុជា*

*រូបភាព ២÷ ស្ថានភាពអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៣. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ

*តារាង ៤÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) (គិតជាប៊ីលានរៀល)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| **I. ចំណូលក្នុងប្រទេស** | **6,014.14** | **11.1%** | **-3.9%** | **-1.6%** |
| **១. ចំណូលចរន្ត** | **6,002.03** | **11.0%** | **-3.9%** | **-1.6%** |
| ក. ចំណូលសារពើពន្ធ | 5,276.56 | 9.9% | -2.9% | -2.9% |
| ខ. ចំណូលមិនមែនសារពើពន្ធ | 725.47 | 20.3% | -10.5% | 11.5% |
| **២. ចំណូលមូលធន** | **12.11** | **30.5%** | **9.6%** | **-3.5%** |
| **II. ចំណាយសរុប** | **9,955.60** | **39.1%** | **10.9%** | **11.2%** |
| **១. ចំណាយចរន្ត** | **6,131.21** | **31.5%** | **9.1%** | **11.9%** |
| ក. ការពារ និងសន្តិសុខជាតិ | 1,314.52 | 18.4% | -17.2% | 0.9% |
| ខ. រដ្ឋបាលស៊ីវិល | 4,693.72 | 41.8% | 18.8% | 15.7% |

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| គ. ចំណាយការប្រាក់ | 122.96 | -48.9% | 48.7% | 15.1% |
| **២. ចំណាយមូលធន** | **3,824.39** | **53.4%** | **13.9%** | **10.0%** |
| ឱនភាពចរន្ត (សាច់ប្រាក់) | (129.18) | -117.4% | -120.6% | -36.3% |
| ឱនភាពទូទៅ (សាច់ប្រាក់) | (3,941.46) | 126.5% | 44.8% | 108.4% |
| **III. ហិរញ្ញប្បទាន** | **3,941.46** | **126.5%** | **44.8%** | **108.4%** |
| ១. ហិរញ្ញប្បទានក្រៅស្រុក | 1,762.94 | 180.0% | 24.1% | 3.4% |
| ២. ហិរញ្ញប្បទានក្នុងស្រុក | 49.64 | 40.0% | -191.3% | -224.0% |
| ៣. ប្រតិបត្តិការកំពុងដំណើរការ | 2,128.88 | 98.0% | 57.2% | -127.8% |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៣÷ស្ថានភាពហិរញ្ញវត្ថុសាធារណៈ (គិតជាប៊ីលានរៀល)*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន

*តារាង ៥៖ ស្ថានភាពរូបិយវត្ថុ (គិតជាប៊ីលានរៀល)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **60,108.50** | **18.9%** | **56.9%** | **13.8%** |
| ឥណទេយ្យពីអនិវាសជន | 108,356.65 | 7.9% | 19.1% | 6.1% |
| ទ្រព្យអកម្មចំពោះអនិវាសជន | (48,248.14) | -3.2% | -8.4% | -0.5% |
| **ឥណទេយ្យក្នុងស្រុក** | **213,579.65** | **0.4%** | **4.8%** | **9.6%** |
| ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល | (21,415.16) | 1.8% | -2.5% | 0.6% |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | 335.05 | 5.0% | 89.6% | 117.2% |
| ទ្រព្យអកម្មរដ្ឋាភិបាល | (21,750.22) | 1.9% | -1.7% | 1.3% |
| ឥណទេយ្យសុទ្ធចំពោះវិស័យផ្សេងៗ | 234,994.81 | 0.5% | 4.1% | 8.7% |
| ឥណទេយ្យចំពោះរដ្ឋាភិបាលថ្នាក់ក្រោមជាតិ | - | - | - | - |
| ឥណទេយ្យចំពោះគ្រឹះស្ថានសាធារណៈមិនមែនហិរញ្ញវត្ថុ | 33.69 | 604.8% | 1771.3% | -63.9% |
| ឥណទេយ្យចំពោះវិស័យឯជន | 234,961.12 | 0.5% | 4.1% | 8.7% |
| **ទ្រព្យអកម្មជារូបិយវត្ថុទូទៅ (M2)** | **193,530.49** | **3.4%** | **12.5%** | **10.0%** |
| *ក្នុងនោះជារូបិយប័ណ្ណបរទេស* | 161,308.14 | 3.6% | 13.0% | 9.7% |
| រូបិយវត្ថុ (M1) | 42,890.96 | 1.4% | 3.8% | -1.3% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | 14,974.98 | 3.2% | 5.9% | 4.2% |
| ប្រាក់បញ្ញើចរន្ត | 27,915.98 | 0.5% | 2.7% | -4.1% |
| ប្រាក់បញ្ញើផ្សេងទៀត | 150,639.53 | 3.9% | 15.3% | 14.0% |
| មូលបត្រមិនមែនភាគហ៊ុន | - | - | - | - |
| **ទុនបម្រុងជារូបិយប័ណ្ណបរទេសដុល (លានដុល្លារអាម៉េរិក)** | **19,998.38** | **10.7%** | **12.3%** | **-1.0%** |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

## រូបភាព ៤÷ ស្ថានភាពរូបិយវត្ថុប្រចាំត្រីមាស




ប្រភព: ធនាគារជាតិនៃកម្ពុជា

## តារាង ៦÷ ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជ (គិតជាប៊ីលានរៀល)

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 7,834.78 | -2.7% | -5.6% | 0.3% |
| ធនាគារជាតិនៃកម្ពុជា | - | - | - | - |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | 5,979.65 | -3.1% | -2.8% | 1.9% |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត | 1,855.13 | -1.3% | -13.7% | -4.2% |
| គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ | 160,915.00 | 1.6% | 15.1% | 14.2% |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 19,248.18 | 0.4% | 23.4% | 19.9% |
| ឧស្សាហកម្មរ៉ែ | 1,089.07 | 3.2% | 17.9% | 15.5% |
| កម្មន្តសាល | 9,333.46 | 1.9% | 13.7% | 18.7% |
| ការផ្គត់ផ្គង់សេវាសាធារណៈ | 2,415.37 | -1.6% | 24.3% | 20.2% |
| សំណង់ | 20,829.18 | 2.3% | 14.2% | 12.4% |
| ការជួញដូរដុំ | 19,278.30 | 3.2% | 3.6% | 6.6% |
| ការជួញដូររាយ | 37,170.58 | 0.2% | 20.4% | 18.1% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 8,406.37 | -0.9% | -0.2% | 4.0% |

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | 6,060.39 | -0.4% | 21.5% | 16.0% |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | 1,073.03 | -4.4% | 4.2% | 1.6% |
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ | 2,854.52 | 3.3% | 3.0% | -3.1% |
| ការជួញដូរអចលនទ្រព្យ | 22,177.52 | 4.4% | 22.1% | 19.7% |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ | 10,979.03 | 2.6% | 9.2% | 10.1% |
| តម្រូវការផ្ទាល់ខ្លួន | 49,712.30 | 0.1% | 14.1% | 12.8% |
| ការឱ្យខ្ចីជាបុគ្គល | 20,544.59 | 1.7% | 32.6% | 14.5% |
| ការឱ្យខ្ចីតាមបណ្ណឥណទាន | 709.19 | 10.7% | 34.4% | 38.4% |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | 28,458.53 | -1.2% | 3.3% | 11.4% |
| ឥណទានផ្សេងៗ | 2,753.31 | -0.6% | 52.2% | 44.2% |
| **សរុប** | **221,215.39** | **0.5%** | **13.9%** | **13.5%** |
| *ក្នុងនោះជារៀល* | *24,830.01* | *2.7%* | *18.4%* | *13.7%* |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

*រូបភាព ៥៖ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជប្រចាំត្រីមាស*




ប្រភព: ធនាគារជាតិនៃកម្ពុជា

*តារាង ៧÷ ស្ថានភាពឥណទានផ្តល់ដោយមីក្រូហិរញ្ញវត្ថុ (គិតជាប៊ីលានរៀល)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| ស្ថាប័នហិរញ្ញវត្ថុ | 30.25 | -1.3% | -11.5% | -19.7% |
| កសិកម្ម | 4,655.68 | -1.4% | -32.9% | -9.6% |
| កម្មន្តសាល | 608.49 | 2.4% | -14.6% | 5.4% |
| ពាណិជ្ជកម្ម | 4,273.04 | -0.9% | -52.9% | -20.3% |
| គ្រួសារ | 6,464.31 | -0.9% | 22.5% | -0.9% |
| សេវាកម្ម | 2,408.86 | 0.0% | 39.9% | -6.8% |
| ដឹកជញ្ជូន | 606.50 | -2.2% | -65.5% | -32.3% |
| សំណង់ | 1,496.22 | -0.8% | -88.4% | -63.3% |
| ឥណទានផ្សេងៗ | 492.95 | -6.3% | 0.3% | 6.0% |
| **សរុប** | **21,036.28** | **-1.0%** | **-46.0%** | **-16.5%** |

ប្រភព: ធនាគារជាតិនៃកម្ពុជា

*រូបភាព ៦÷ចំណែក នៃឥណទានតាមវិស័យផ្តល់ដោយមីក្រូហិរញ្ញវត្ថុប្រចាំត្រីមាស*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៥. ស្ថានភាពពាណិជ្ជកម្ម

*តារាង ៨÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាលានដុល្លារអាមេរិក)*

| មុខទំនិញ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| ថ្នាំពេទ្យ | 78.10 | 2.7% | -7.5% | -8.6% |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 152.13 | 14.3% | 4.7% | -2.2% |
| ស្ករស និងប៊ីចេង | 27.87 | 19.2% | 28.6% | 24.3% |
| ប្រេងឆា និងអាហារផ្សេងៗ | 187.34 | 1.4% | 15.8% | 12.3% |
| គ្រឿងសំណង់ | 473.47 | -4.3% | 3.3% | 1.4% |
| គ្រឿងអេឡិចត្រូនិក | 292.04 | 15.7% | 12.9% | 14.7% |
| វាយនភណ្ឌនិងសម្លៀកបំពាក់ | 1,292.86 | 0.1% | 12.9% | -6.9% |
| យានយន្ត | 212.24 | -10.4% | -45.0% | -37.1% |
| គ្រឿងបន្លាស់ថយន្ត | 6.66 | -18.1% | -21.3% | 63.8% |
| បរិក្ខារត្រជាក់ | 20.33 | 13.8% | -44.4% | -2.9% |
| ប្រេងឥន្ធនៈ | 669.92 | 6.0% | 9.0% | -7.9% |
| មាស | 168.90 | 206.2% | 110.8% | -95.0% |
| ជីកសិកម្ម | 90.45 | 1.7% | 16.3% | 17.7% |
| ផ្សេងៗ | 2,462.99 | -3.3% | -8.7% | -3.5% |
| **សរុប** | **6,135.31** | **1.5%** | **-0.7%** | **-18.5%** |

ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៧÷ ទំហំនាំចូលគ្រឿងសំណង់, ប្រេងឥន្ធនៈ, យានយន្ត និង វាយនភណ្ឌនិងសម្លៀកបំពាក់ (លានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៨÷ ស្ថានភាពនាំចូលពីទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង ៩÷ មុខទំនិញនាំចេញ (គិតជាលានដុល្លារអាមេរិក)*

| មុខទំនិញ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| សម្លៀកបំពាក់ | 1,939.27 | -14.8% | 4.2% | -12.9% |
| ស្បែកជើង | 373.70 | 28.3% | -9.4% | -21.4% |
| កាបូប | 409.32 | -3.2% | 11.4% | -8.1% |
| វាយនភណ្ឌផ្សេងៗ | 69.03 | -9.7% | 15.6% | -2.0% |
| គ្រឿងអេឡិចត្រូនិក និងភាគបំណែក | 49.65 | -11.8% | 22.7% | 5.3% |
| គ្រឿងបន្លាស់រថយន្ត | 65.03 | 5.2% | 28.1% | 37.2% |
| កង់ | 56.86 | -30.1% | -71.6% | -53.7% |
| ឈើម្សូល | 0.02 | -95.2% | -92.6% | -53.0% |
| ឈើកែច្នៃ (Veneer) | 0.00 | - | -100.0% | -82.0% |
| ក្តារបន្ទះ | 58.07 | 2.2% | 26.6% | -5.4% |
| ឈើកែច្នៃផ្សេងទៀត | 98.42 | 3.0% | 46.9% | 17.0% |
| អង្ករ | 139.52 | 41.0% | 12.0% | 12.4% |
| ដំឡូងមី | 212.42 | 84.9% | 167.7% | 57.2% |
| ពោតក្រហម | 2.04 | -92.2% | 2046.9% | 5488.7% |
| សណ្តែក | 9.27 | 3881.0% | 175.2% | 144.5% |
| ចេក | 35.80 | 34.3% | 16.8% | -20.3% |
| ស្វាយ | 34.83 | 384.1% | 27.4% | -0.3% |
| ស្វាយចន្ទី | 4.42 | -84.5% | -56.4% | 51.5% |
| កៅស៊ូ | 193.81 | 37.2% | 42.7% | 28.6% |
| ស្ករស | 44.36 | 140.0% | 2528.2% | 127.1% |
| ផលិតផលជលផល | 0.21 | 60.5% | 111.3% | 49.0% |
| កសិផលផ្សេងទៀត | 19.90 | -1.2% | 39.5% | -30.7% |
| បារី | 1.29 | -22.2% | 12.4% | 12.3% |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 31.07 | -42.0% | -59.4% | -30.1% |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0.64 | 194.3% | 410.4% | 139.9% |
| មាស | 174.21 | 57.9% | 243.8% | 256.2% |
| ផ្សេងៗ | 1,850.24 | -10.5% | 18.3% | 37.3% |
| **សរុប** | **5,873.40** | **-4.2%** | **12.4%** | **4.4%** |

ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៩÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ១០÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៦. ស្ថានភាពវិនិយោគឯកជន

*តារាង ១០÷ ស្ថិតិវិនិយោគវិស័យឯកជន (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| **គម្រោងវិនិយោគសរុប** | **គម្រោង** | **52** | **-33.3%** | **44.4%** | **30.6%** |
| **បង្កើតការងារសរុប** | **កន្លែង** | **49,421** | **-52.6%** | **58.2%** | **96.8%** |
| **ទុនវិនិយោគសរុប** | **លានដុល្លារអាមេរិក** | **936.66** | **-21.9%** | **328.7%** | **51.0%** |
| **ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស** | | | | | |
| គម្រោងវិនិយោគ | គម្រោង | 21 | -8.7% | 133.3% | 65.1% |
| បង្កើតការងារ | កន្លែង | 13,462 | -45.2% | 437.2% | 241.3% |
| ទុនវិនិយោគលើវិស័យឧស្សាហកម្ម | លានដុល្លារអាមេរិក | 104.59 | -68.7% | 214.7% | 26.6% |
| **ការវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស** | | | | | |
| គម្រោងវិនិយោគ | គម្រោង | 31 | -43.6% | 14.8% | 20.3% |
| បង្កើតការងារ | កន្លែង | 35,959 | -54.9% | 25.1% | 76.7% |
| ទុនវិនិយោគលើវិស័យ | លានដុល្លារអាមេរិក | 832.07 | -3.8% | 349.1% | 60.5% |
| កសិកម្ម | លានដុល្លារអាមេរិក | 10.48 | -23.7% | -76.3% | 61.6% |
| ថាមពល | លានដុល្លារអាមេរិក | 513.06 | - | - | 31.8% |
| ឧស្សាហកម្ម | លានដុល្លារអាមេរិក | 280.81 | -63.0% | 106.6% | 60.4% |
| សេវាកម្ម | លានដុល្លារអាមេរិក | - | - | -100.0% | -100.0% |
| ទេសចរណ៍ | លានដុល្លារអាមេរិក | 27.72 | -69.6% | - | - |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC), សម្គាល់ការអនុញ្ញាតវិនិយោគសរុប ដោយរួមបញ្ចូលការពង្រីកគម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេស

*រូបភាព ១១÷ស្ថានភាពវិនិយោគឯកជន*




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

## ២.៧. ស្ថានភាពទេសចរណ៍

*តារាង ១១÷ ចំនួនភ្ញៀវទេសចរអន្តរជាតិ*

| បរិយាយ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| តាមផ្លូវអាកាស | នាក់ | 525,529 | 22.8% | 62.8% | 235.8% |
| ភ្នំពេញ | នាក់ | 366,853 | 13.3% | 64.0% | 224.0% |
| សៀមរាប | នាក់ | 154,924 | 54.6% | 62.8% | 293.5% |
| កងកេង | នាក់ | 3,752 | -3.1% | -2.2% | 94.0% |
| តាមផ្លូវគោក និងផ្លូវទឹក | នាក់ | 1,000,820 | 8.9% | 45.4% | 241.5% |
| ផ្លូវគោក | នាក់ | 975,590 | 7.2% | 43.8% | 240.0% |
| ផ្លូវទឹក | នាក់ | 25,230 | 168.4% | 163.8% | 370.9% |
| **សរុប** | **នាក់** | **1,526,349** | **13.3%** | **51.0%** | **239.5%** |

ប្រភព: ក្រសួងទេសចរណ៍

*រូបភាព ១២÷ កំណើនភ្ញៀវទេសចរអន្តរជាតិ (គិតជា %)*




ប្រភព: ក្រសួងទេសចរណ៍

*រូបភាព ១៣÷ កំណើនភ្ញៀវទេសចរអន្តរជាតិពីតំបន់នីមួយៗ (គិតជា %)*




ប្រភព: ក្រសួងទេសចរណ៍

## ២.៨. ស្ថានភាពសំណង់

*តារាង ១២÷ សំណង់ទូទាំងប្រទេស*

| បរិយាយ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| សំណង់សាធារណៈ | គម្រោង | 15 | 50.0% | -11.8% | 5.2% |
| សំណង់លំនៅឋាន និងភូមិគ្រឹះ | គម្រោង | 536 | -9.3% | -43.2% | -28.3% |
| សំណង់ឧស្សាហកម្ម | គម្រោង | 26 | -60.6% | -52.7% | 3.3% |
| សំណង់ពាណិជ្ជកម្ម | គម្រោង | 27 | -55.0% | -63.0% | -13.2% |
| សំណង់ទេសចរណ៍ | គម្រោង | 5 | -73.7% | -58.3% | 52.8% |
| សំណង់វិនិយោគផ្សេងៗ | គម្រោង | - | -100.0% | - | 200.0% |
| **សរុប** | **គម្រោង** | **609** | **-18.7%** | **-44.6%** | **-25.0%** |
| **ក្រឡាផ្ទៃសាងសង់** | **ម៉ែត្រការ៉េ** | **1,141,042** | **-77.9%** | **-52.7%** | **80.4%** |
| **តម្លៃ** | **លានដុល្លារអាមេរិក** | **501.85** | **-77.2%** | **-50.3%** | **84.0%** |

ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*រូបភាព ១៤÷ ចំណែកនៃផ្ទៃក្រឡាសាងសង់តាមប្រភេទ (គិតជា %)*




ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង ១៣÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យម)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|---|
| | | | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| អង្ករ (បាក់៥%) | ដុល្លារអាមេរិក/ តោន | បាងកក | 610.67 | 1.7% | 36.9% | 26.8% |
| ប្រេងឆៅ | ដុល្លារអាមេរិក/ ធុង | ក្រុងឡុងដ៍ | 82.05 | -3.8% | -3.8% | -16.8% |
| កៅស៊ូ | ដុល្លារអាមេរិក/ តោន | សិង្ហបុរី | 1,461.67 | 9.4% | 12.3% | -10.4% |
| មាស | ដុល្លារអាមេរិក/ អោន | ក្រុងឡុងដ៍ | 2,167.41 | 2.4% | 14.3% | 7.9% |
| ពោតក្រហម | ដុល្លារអាមេរិក/ តោន | ស៊ីកាហ្គោ | 216.17 | -3.8% | -32.9% | -20.7% |
| សណ្តែកសៀង | ដុល្លារអាមេរិក/ តោន | ស៊ីកាហ្គោ | 543.35 | -11.3% | -15.1% | -11.5% |
| ប្រេងដូង | ដុល្លារអាមេរិក/ តោន | រ៉ុតធើដាំ | 1,089.93 | 1.6% | -4.9% | -34.2% |
| ស្ករស | ដុល្លារអាមេរិក/ តោន | ក្រុងឡុងដ៍ | 351.39 | -1.1% | 5.5% | 2.6% |

ប្រភព៖ គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*រូបភាព១៥ ÷ ទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យម)*




ប្រភព៖ គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*តារាង ១៤÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| **មិនមែនថាមពល** | **107.78** | **-2.2%** | **-5.7%** | **-10.8%** |
| ផលិតផលកសិកម្ម | 109.12 | -2.9% | -5.7% | -7.8% |
| ម្ហូបអាហារ | 122.08 | -5.0% | -10.8% | -15.7% |
| ឈើ | 78.13 | -2.0% | 3.5% | -2.2% |
| លោហៈធាតុ | 100.67 | -0.1% | -0.9% | 2.2% |
| ជីគីមី | 146.10 | -4.9% | -27.6% | -39.6% |

ប្រភពៈ គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*រូបភាព១៦ ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*




*ចំណាំ÷អាហារ (ធញ្ញជាតិ, ប្រេងឆា និងអាហារផ្សេងៗ), ភេសជ្ជៈ (កាកាវ, កាហ្វេ និងតែ), វត្ថុធាតុដើម (ឈើមូល, កប្បាស, កៅស៊ូ និងថ្នាំជក់)*

ប្រភពៈ គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*តារាង ១៥÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (ជាមធ្យមប្រចាំត្រីមាស)*

| រូបិយប័ណ្ណ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៤ | ត្រីមាសមុន | ត្រីមាសទី៤ឆ្នាំមុន | ឆ្នាំមុន |
| ជប៉ុន (Yen) | 145.89 | 0.3% | 4.8% | 7.0% |
| ហុងកុង (Dollar) | 7.81 | -0.2% | -0.1% | 0.0% |
| សិង្ហបុរី (Dollar) | 1.34 | -0.7% | -2.6% | -2.8% |
| ម៉ាឡេស៊ី (Ringgit) | 4.67 | 0.9% | 2.8% | -2.7% |
| ហ្វីលីពីន (Peso) | 55.77 | -0.5% | -1.6% | -6.1% |
| ថៃ (Baht) | 35.03 | -0.6% | -2.5% | -1.1% |
| ឥណ្ឌូនេស៊ី (Rupiah) | 15,552.00 | 1.9% | -0.3% | 2.0% |
| កូរ៉េខាងត្បូង (Won) | 1,310.74 | -0.2% | -1.9% | 1.2% |
| តៃវ៉ាន់ (Dollar) | 31.37 | -1.3% | 0.4% | 4.1% |
| ចិន (Yuan Renminbi) | 7.15 | -1.2% | 0.5% | 4.8% |
| ឡាវ (Kip) | 20,462.53 | 4.8% | 19.9% | 30.7% |
| វៀតណាម (Dong) | 24,355.00 | 1.3% | -0.2% | 1.8% |
| ឥណ្ឌា (Rupee) | 83.21 | 0.6% | 1.2% | 4.8% |
| រុស្ស៊ី (Ruble) | 90.34 | -4.9% | 25.3% | 22.1% |
| អូស្ត្រាលី (Dollar) | 1.52 | -1.1% | 0.5% | 4.3% |
| អង់គ្លេស (Pound) | 0.80 | 0.5% | -5.0% | -1.6% |
| អឺរ៉ុប (Euro) | 0.92 | -0.3% | -5.0% | -4.0% |

ប្រភព: គេហទំព័រអូអែនដា (www.oanda.com)